# តើគេអាចចុះកិច្ចសន្យាក្នុងនាម និងតំណាងឲ្យក្រុមហ៊ុនមួយ ដែលមិនទាន់បានបង្កើត ឬចុះក្នុងបញ្ជីពាណិជ្ជកម្មបានដែរឬទេ?

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មាត្រា ៩៨ ចែងថាក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ (ភាពពេញលក្ខណៈ ជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច) ចាប់ពីកាលបរិច្ឆេទដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម។ ជាទូទៅ យើងអាចរកមើលកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនមួយនៅលើវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម ឬគេហទំព័ររបស់ក្រសួងពាណិជ្ជកម្មផងដែរ។ ច្បាប់ដដែល ត្រង់មាត្រា ៩៩ បានបញ្ជាក់បន្ថែមថា ក្រុមហ៊ុនដែលបង្កើតឡើងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមានសមត្ថភាព សិទ្ធិ និងបុព្វសិទ្ធិដូចរូបវន្តបុគ្គលដែរ ហើយអាចប្រកបអាជីវកម្ម ឬធ្វើពាណិជ្ជកិច្ចទូទាំងព្រះរាជាណាចក្រកម្ពុជាបាន។

តាមបញ្ញត្តិខាងលើ ក្រុមហ៊ុនមិនមានសមត្ថភាពជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច ហើយក៏មិនមានសិទ្ធិធ្វើពាណិជ្ជកិច្ចនៅកម្ពុជាបានដែរ ប្រសិនបើក្រុមហ៊ុននោះមិនបានចុះក្នុងបញ្ជីពាណិជ្ជកម្ម។ ដូចគ្នានេះដែរ ក្រុមហ៊ុនដែលបានបង្កើតនៅបរទេស ប៉ុន្តែមិនបានចុះបញ្ជីពាណិជ្ជកម្មស្របទៅតាមច្បាប់កម្ពុជា ក៏មិនអាចធ្វើពាណិជ្ជកិច្ចនៅកម្ពុជាបានដែរ។ ហេតុនេះ ជាគោលការណ៍ ប្រសិនបើក្រុមហ៊ុនមួយមិនទាន់បានចុះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុននោះក៏មិនអាចចុះកិច្ចសន្យាបានដែរ។ តើគេអាចចុះកិច្ចសន្យាក្នុងនាម និងតំណាងឲ្យក្រុមហ៊ុនមួយ ដែលមិនទាន់បានបង្កើត ឬចុះបញ្ជីពាណិជ្ជកម្មបានដែរឬទេ? ដើម្បីសម្របសម្រួលដល់ការរៀបចំបង្កើតក្រុមហ៊ុន មាត្រា ១៣៩ នៃច្បាប់ដដែលបានផ្តល់នូវដំណោះស្រាយមួយ ដែលអាចឲ្យរូបវន្តបុគ្គលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនមុនពេលក្រុមហ៊ុននោះមានអត្ថិភាព។ ក៏ប៉ុន្តែប្រសិនបើយើងសាកល្បងអានមាត្រានេះ យើងអាចនឹងឃើញថាមាត្រានេះពិបាកយល់បន្តិច។ អត្ថបទនេះព្យាយាមពិភាក្សាអំពីមាត្រានេះ ដូចខាងក្រោម៖

មាត្រា ១៣៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចែងថា បុគ្គលម្នាក់ៗដែលបានចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ក្នុងនាម ឬតំណាងឲ្យក្រុមហ៊ុន មុនពេលក្រុមហ៊ុននោះមានអត្ថិភាព បុគ្គលនោះត្រូវជាប់កាតព្វកិច្ចដោយផ្ទាល់នៅក្នុងកិច្ចសន្យានោះ និងមានសិទ្ធិក្នុងការទទួលផលប្រយោជន៍នោះដែរ។ ឧទាហរណ៍ ក្នុងករណីដែលម្ចាស់ភាគហ៊ុនបានចុះហត្ថលេខាលើកិច្ចសន្យាជួលអគារដើម្បីប្រកបអាជីវកម្ម ក្នុងនាមក្រុមហ៊ុនមុនពេលដែលក្រុមហ៊ុនត្រូវបានបង្កើត ឬត្រូវបានចុះបញ្ជី បុគ្គលដែលជាម្ចាស់ភាគហ៊ុននោះ ត្រូវបានចងភ្ជាប់ជាមួយនឹងកាតព្វកិច្ចដោយកិច្ចសន្យាជួលអាគារនោះ

ក្នុងនាមខ្លួនឯងផ្ទាល់ និងទទួលបានអត្ថប្រយោជន៍ពីកិច្ចសន្យាជួលនេះ។ តាមវិធានខាងលើ យើងអាចបកស្រាយថា ប្រសិនបើក្រោយមក ក្រុមហ៊ុនមិនត្រូវបានបង្កើត ឬមិនត្រូវបានចុះបញ្ជីពាណិជ្ជកម្មទេនោះ បុគ្គលដែលបានអះអាងថាបានធ្វើសកម្មភាពតំណាងក្រុមហ៊ុននោះ ត្រូវក្លាយជាភាគីនៃកិច្ចសន្យាជួលអាគារនោះក្នុងនាមខ្លួនឯងផ្ទាល់។

ច្បាប់ដដែល មាត្រា ១៣៩ កថាខណ្ឌទី២ ចែងថាក្រោយពីកិច្ចសន្យាមួយបានបង្កើតឡើងក្នុងពេលវេលាមួយសមស្រប ក្រុមហ៊ុនដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្មរួចហើយនោះ អាចទទួលយកនូវកិច្ចសន្យាដែលបានធ្វើឡើងមុនពេលក្រុមហ៊ុនមានអត្ថិភាពបាន តាមរយៈសកម្មភាព ឬការប្រព្រឹត្តណាមួយ ដែលបង្ហាញពីបំណង ឬឆន្ទៈរបស់ក្រុមហ៊ុនក្នុងការទទួលយកកិច្ចសន្យានោះ និងចងភ្ជាប់ក្រុមហ៊ុនទៅនឹងកាតព្វកិច្ចនៃកិច្ចសន្យានោះ។ នៅក្នុងការអនុវត្ត ក្រុមហ៊ុនអាចអនុម័តទទួលយកកិច្ចសន្យាដែលបានបង្កើតមុនពេលក្រុមហ៊ុនមានអត្ថិភាព ឬយល់ព្រមជាប់កាតព្វកិច្ចទៅនឹងកិច្ចសន្យា តាមរយៈការចេញសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសេចក្ដីសម្រេចម្ចាស់ភាគហ៊ុនដែលបញ្ជាក់ពីគោលបំណង ឬឆន្ទៈរបស់ក្រុមហ៊ុនទទួលយកកិច្ចសន្យា។ ម៉្យាងទៀត ប្រសិនបើមិនបានបង្ហាញឆន្ទៈជាលាយលក្ខណ៍អក្សរ ក្រុមហ៊ុនក៏អាចធ្វើសកម្មភាពណាដែលបញ្ជាក់ពីការទទួលស្គាល់កិច្ចសន្យានោះ ដូចជាការអនុវត្តតាមកិច្ចសន្យានិងការទទួលផលប្រយោជន៍ពីកិច្ចសន្យានោះជាដើម។ ជាលទ្ធផល ក្រុមហ៊ុនត្រូវបានចងភ្ជាប់ដោយកិច្ចសន្យា ហើយមានសិទ្ធិទទួលបានអត្ថប្រយោជន៍នៃកិច្ចសន្យា ប្រៀបបីដូចជាក្រុមហ៊ុននោះមានអត្ថិភាពនៅកាលបរិច្ឆេទនៃការចុះកិច្ចសន្យានោះដែរ។ (មាត្រា១៣៩ កថាខណ្ឌទី៣) ចំណែកឯបុគ្គលដែលបានអនុវត្តក្នុងនាម ឬតំណាងឲ្យក្រុមហ៊ុន នឹងលែងមានកាតព្វកិច្ច ឬសិទ្ធិទទួលផលប្រយោជន៍នៅក្នុងកិច្ចសន្យានោះទៀតហើយ។ (មាត្រា១៣៩ កថាខណ្ឌទី៤)

សូមបញ្ជាក់ថាប្រសិនបើពុំមានការបញ្ជាក់ច្បាស់លាស់ទេ មាត្រាដែលបានយោងក្នុងអត្ថបទនេះ សំដៅដល់មាត្រា ឬបញ្ញត្តិនៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។ អត្ថបទនេះមិនមែនជាការផ្ដល់ប្រឹក្សាផ្នែកច្បាប់ ឬការផ្ដល់យោបល់ផ្នែកច្បាប់ឡើយ។ ប្រសិនបើលោកអ្នកជួបបញ្ហាដូចបានរៀបរាប់ខាងលើនេះ សូមស្វែងរកការប្រឹក្សាផ្នែកច្បាប់ពីមេធាវី។